ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទ
# ព្លៅអភិវឌ្ឍន៍បឹងកណ្តាល និង ឯកសារពាក់ព័ន្ធ

# បញ្ជីអត្ថបទ


១-កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទ

២-ផែនទីកន្លែងនេសាទសហគមន៍

៣-បញ្ជីឈ្មោះសមាជិកនិង គណៈកម្មការសហគមន៍នេសាទ

៤-លក្ខន្តិកៈ សហគមន៍នេសាទ

៥-បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

៦-សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ

៧-លិខិតស្នើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

៨-ឯកសារផ្សេងៗ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេសាទ ព្នៅអភិវឌ្ឍន៍បឹងកណ្ដាល

ឈ្មោះសហគមន៍នេសាទ : **ព្នៅអភិវឌ្ឍន៍បឹងកណ្ដាល**

ភូមិ : *ព្នៅ*

ឃុំ : *ព្នៅ*

ស្រុក : *សន្ទុក*

ខេត្ត : *កំពង់ធំ*

# កិច្ចព្រមព្រៀង
# កន្លែងនេសាទសហគមន៍

## រវាង

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ** ជាតំណាងស្របច្បាប់នៃរដ្ឋបាលជលផល មានអាសយដ្ឋាននៅភូមិកំពង់ធំ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ទូរស័ព្ទលេខ ០៦២ ៩៦១ ២៩២ អ៊ីម៉ែល.........ទូរសារលេខ............ហៅថា " ភាគី **ក** "។

## និង

ប្រធានគណៈកម្មការសហគមន៍នេសាទ**ញ្ញៅអភិវឌ្ឍន៍បឹងកណ្តាល** ជាតំណាងស្របច្បាប់ឱ្យសហគមន៍នេសាទ ដែលមានអាសយដ្ឋានស្ថិតនៅភូមិញ្ញៅ ឃុំញ្ញៅ ស្រុកសន្ទុក ទូរស័ព្ទលេខ :......................ហៅថា "ភាគី **ខ**"។

ភាគីទាំងពីរបានឯកភាពគ្នាចុះកិច្ចព្រមព្រៀងតាមលក្ខខណ្ឌដូចខាងក្រោម ៖

**ប្រការ ១.-**

ភាគី **ក** ប្រគល់ដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យភាគី **ខ** ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរយៈពេល ៣ ឆ្នាំ ចាប់ពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១០ ដោយធានានូវចីរភាពតាមរយៈការរៀបចំសហគមន៍នេសាទ។

**ប្រការ ២.-**

ដែននេសាទនេះ មានឈ្មោះថា"***កន្លែងនេសាទសហគមន៍ញ្ញៅអភិវឌ្ឍន៍បឹងកណ្តាល***" ដែលលាតសន្ធឹងនៅក្នុងភូមិញ្ញៅ ឃុំញ្ញៅ ស្រុកសន្ទុក ខេត្តកំពង់ធំ មាននិយាមកាដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀងនេះ និងដូចនៅលើផែនទីដែលបានភ្ជាប់មកជាមួយ។

**ប្រការ ៣.-**

ភាគី **ក** ត្រូវបំពេញភារកិច្ចជាអ្នកជួយសម្របសម្រួលផ្តល់បច្ចេកទេស ទប់ស្កាត់បទល្មើស តាមដាន និងត្រួតពិនិត្យលើការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគមន៍នេសាទដូចមានចែងនៅក្នុងមាត្រា ២៣ នៃអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

**ប្រការ ៤.-**

ភាគី **ខ** ត្រូវរៀបចំ ៖

- កន្លែងអភិរក្សព្រៃលិចទឹក
- កន្លែងអភិរក្សអន្លង់មេត្រីពូជ
- កន្លែងអភិរក្សជីវចំរុះ
- ស្តារប្រឡាយ ព្រែក បឹង ស្រះ
- ដាំព្រៃលិចទឹក
- ធ្វើវារីវប្បកម្ម
- បញ្ជូនសមាជិកសហគមន៍ដើម្បីរៀនសូត្រនូវបច្ចេកទេសផលិតពូជត្រី
- ការងារអភិវឌ្ឍន៍ផ្សេងៗទៀត។

**ប្រការ ៥.-**

ភាគី ខ ត្រូវរៀបចំប្រជុំពិភាក្សាអំពីទំហំ ចំនួន ប្រវែង និង ប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ឱ្យសមស្របតាមស្ថានភាពភូមិសាស្ត្រ និងពេលវេលាផ្អែកតាមច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ។

**ប្រការ ៦.-**

ភាគី ខ មានកាតព្វកិច្ចថែរក្សាការពារធនធានធម្មជាតិដូចខាងក្រោម ៖

- ការពារព្រៃលិចទឹក ដែលមានស្រាប់ឱ្យបានគង់វង្ស ចាត់វិធានការទប់ស្កាត់ និងបង្ការភ្លើងឆេះព្រៃ
- រក្សា និងការពារដីទំនាបលិចទឹកសម្រាប់ដាំព្រៃលិចទឹកឡើងវិញ
- លែងទៅក្នុងធម្មជាតិវិញនូវវារីសត្វដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ នៅពេលដែលធ្វើនេសាទបាន
- ការពារសត្វព្រៃគ្រប់ប្រភេទនៅក្នុងដែននេសាទ ឬព្រៃលិចទឹក។

**ប្រការ ៧.-**

ភាគី ខ មិនត្រូវធ្វើសកម្មភាពដែលបង្កឱ្យខូចដែននេសាទ ឬគ្រោះថ្នាក់ដល់ធនធានជលផល ដូចខាងក្រោម ៖

- ចាប់នូវធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជា ផ្សោត ត្រីគល់រាំង ត្រីរាជជាដើម
- លើកទំនប់ លុប ឬជីក បឹង ព្រែក ប្រឡាយ រណ្តៅ បៀ ស្រះ ដែលពុំមានការអនុញ្ញាតពីស្ថាប័នជំនាញ
- កាប់ ឆ្ការ គាស់ រាន ឈូសឆាយព្រៃលិចទឹកក្នុងគោលបំណងហ៊ុមព័ទ្ធយកដីជាកម្មសិទ្ធិ ឬ រាតដីធ្វើស្រែចំការ ឬគោលបំណងផ្សេងៗឡើយ
- ធ្វើនេសាទ កាប់ព្រៃ ឬអុសក្នុងកន្លែងអភិរក្សជលផលក្នុងកន្លែងនេសាទសហគមន៍
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ជាពិសេសឧបករណ៍នេសាទឆក់ត្រី និងឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ
- ប្រើប្រាស់ឧបករណ៍នេសាទខុសពីការកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃកិច្ចព្រមព្រៀងនេះ
- ចិញ្ចឹមត្រី ឬធ្វើស្រែប្រាំងប្រើថ្នាំសម្លាប់ស្មៅ ឬសត្វល្អិត ឬការបំពុលបរិស្ថានផ្សេងៗទៀតដែលនាំឱ្យខូចដល់បរិស្ថានធម្មជាតិ សុខភាព និងបំផ្លិចបំផ្លាញ ដល់ធនធានជលផល ឬបង្កអន្តរាយដល់ដែននេសាទ
- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ ឈិបយន្ត និងអួនអូសទឹកសាប
- ដាក់សម្រាស់ ឬមធ្យោបាយផ្សេងទៀតធ្វើឱ្យត្រី ឬវារីសត្វកុំសម្រាប់ចាប់
- ដាំ ឬថែរក្សាដំណាំឈូកក្នុងដែននេសាទ
- ធ្វើនេសាទដោយមង ឬអួនគ្រប់ប្រភេទ ដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ (១,៥ស.ម) និងធំជាងដប់ប្រាំសង្ទីម៉ែត្រ (១៥ស.ម) ក្នុងកន្លែងនេសាទសហគមន៍។

**ប្រការ ៨.-**

ភាគី ខ ត្រូវចាត់វិធានការថែរក្សាការពារកន្លែងនេសាទសហគមន៍ដោយបំផុស ជំរុញ និង លើកទឹកចិត្តដល់សមាជិកសហគមន៍នេសាទគ្រប់រូប ឱ្យរាយការណ៍ទៅរដ្ឋបាលជលផលមានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីសហការទប់ស្កាត់បទល្មើសជលផល។

- ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់តាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផល
- សហការយ៉ាងជិតស្និតជាមួយរដ្ឋបាលជលផលមានសមត្ថកិច្ច ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរដែលពាក់ព័ន្ធ ។

**ប្រការ ១០.-**

ប្រសិនភាគី **ខ** មិនអនុវត្តទៅតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ធ្វើឱ្យអន្តរាយដល់ដែននេសាទ ឬធនធានជលផលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

**ប្រការ ១១.-**

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ អាចបញ្ឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងមាត្រា **២៧** នៃអនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។

ក្នុងករណីដែលសហគមន៍នេសាទយល់ថា ការបញ្ឈប់កិច្ចព្រមព្រៀងពុំមានលក្ខណៈសមស្របសហគមន៍នេសាទ អាចធ្វើការតវ៉ាមកប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ។

**ប្រការ ១២.-**

កិច្ចព្រមព្រៀងនេះអាចធ្វើការកែប្រែបានតាមការឯកភាពរបស់ភាគីទាំង២ ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

កិច្ចព្រមព្រៀងនេះ ត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ ការិយាល័យជលផល សាលាខេត្ត រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយអាចចម្លងជូនស្ថាប័នពាក់ព័ន្ធ ដោយច្បាប់ចម្លងត្រូវមានប្រថាប់ត្រាផង ។

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧

| | |
|---|---|
| ភាគី **ក** | ភាគី **ខ** |
| **ជ.នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ** | **ប្រធានគណៈកម្មការសហគមន៍នេសាទ** |
| **ប្រធានការិយាល័យជលផល** | **ហត្ថលេខា** |
| **ហត្ថលេខា** | |

សាក្សី

**មេឃុំព្លៅ**

**ហត្ថលេខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តារាងឧបសម្ព័ន្ធទី ១ សម្រាប់ភ្ជាប់ជាមួយ

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ព្រៃអភិវឌ្ឍន៍បឹងកណ្តោល

ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧

**តារាងនិយាមការព្រំប្រទល់កន្លែងនេសាទសហគមន៍ព្រៃអភិវឌ្ឍន៍បឹងកណ្តោល**

| លេខរៀង | សញ្ញាសំគាល់បង្គោលព្រំប្រទល់ | ចំណុច (UTM) | |
|---|---|---|---|
| | | រយៈទទឹង (N) | រយៈបណ្តោយ (E) |
| ១ | 1 | ៤៨៤៧៥៥ | ១៣៧៨០៤៤ |
| ២ | 2 | ៤៨៦៦៣៩ | ១៣៧៨០៤៤ |
| ៣ | 3 | ៤៨៦៦៤៧ | ១៣៧៦៧៦៣ |
| ៤ | 4 | ៤៨៦៧០៧ | ១៣៧៤៣៩៣ |
| ៥ | 5 | ៤៨៦២៤៣ | ១៣៧៥២២៣ |
| ៦ | 6 | ៤៨៥៩៣៥ | ១៣៧៥២១៩ |
| ៧ | 7 | ៤៨៥៨៩៦ | ១៣៧៤៧៤៨ |
| ៨ | 8 | ៤៨៥៣៥១ | ១៣៧៤៧៧១ |
| ៩ | 9 | ៤៨៤៧៧០ | ១៣៧៥៣៥៩ |
| ១០ | 10 | ៤៨៤៧៦២ | ១៣៧៦៧៧៥ |

កំពង់ធំ ,ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧

**ជ.នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**ប្រធានការិយាល័យជលផល**

ង៉ាន់ ឌីណាង់នី

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ស ចន្ទឿន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តារាងឧបសម្ព័ន្ធទី២ សម្រាប់ភ្ជាប់ជាមួយ

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ព្លៅអភិវឌ្ឍន៍បឹងកណ្តោល

ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧

**តារាងកំណត់ឧបករណ៍នេសាទដែលត្រូវប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ព្លៅអភិវឌ្ឍន៍បឹងកណ្តោល**

| ***ក. រដូវបើកនេសាទចាប់ពីថ្ងៃទី ០១ ខែ តុលា រហូតដល់ថ្ងៃទី ៣១ ខែ ឧសភា*** | |
|---|---|
| **ប្រភេទឧបករណ៍នេសាទ** | **ទំហំ / ប្រវែង / ចំនួន** |
| - មង | ក្រឡាចាប់ពី**ពីរសង្ទីម៉ែត្រកន្លះ** ( ២,៥ស.ម) និងប្រវែងមិនលើសពី**មួយរយម៉ែត្រ** (១០០ម) |
| -អួន | ក្រឡាចាប់ពី**ពីរសង្ទីម៉ែត្រកន្លះ** (២,៥ស.ម) និងប្រវែងមិនលើស**សាមសិបម៉ែត្រ** (៣០ម) |
| -អញ្ចង | ក្រឡាចាប់ពី**ពីរសង្ទីម៉ែត្រកន្លះ** (២,៥ស.ម) និងប្រវែងមិនលើសពី**ប្រាំម៉ែត្រ** (៥ម) |
| -សំណាញ់ | ក្រឡាចាប់ពី**ពីរសង្ទីម៉ែត្រ** (២ស.ម) និងប្រវែងមិនលើស**ពីប្រាំមួយម៉ែត្រ** (៦ម) |
| -សន្ទូចរនង | ចំនួនមិនលើសពី**ពីររយ** (២០០) ផ្លែ |
| -លប | ចំនួនមិនលើសពីដប់ (១០) គ្រឿង |
| -លាន់ | ចំនួនមិនលើសពី**សាមសិប** (៣០) គ្រឿង |

កំពង់ធំ , ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**ជ.នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**ប្រធានការិយាល័យជលផល**

ទ៉ាន់ ឌីណាន់នី

# ផែនទីកន្លែងនេសាទសហគមន៍ ព្រៅអភិវឌ្ឍន៍បឹងកណ្ដាល

## ឃុំព្រៅ ស្រុកសន្ទុក ខេត្តកំពង់ធំ




ព្រៅ, ថ្ងៃទី 24 ខែ 01 ឆ្នាំ២០០7
ប្រធានគណៈកម្មការសហគមន៍ ព្រៅអភិវឌ្ឍន៍បឹងកណ្ដាល

បានឃើញ និង បញ្ជូនមក
លោកមេឃុំ ព្រៅ
"ដើម្បីពិនិត្យ និង សំរួល"
ព្រៅ, ថ្ងៃទី 24 ខែ 01 ឆ្នាំ២០០7
មេភូមិព្រៅ

លេខ 24/07
បានឃើញ និង បញ្ជូនមក
លោកអភិបាលស្រុកសន្ទុក
"ដើម្បីពិនិត្យ និង សំរួល"
ថ្ងៃទី 24 ខែ 01 ឆ្នាំ២០០7
មេឃុំព្រៅ

លេខ
បានឃើញ និង បញ្ជូនមក
លោកប្រធានការិយាល័យជលផល
"ដើម្បីពិនិត្យ និង សំរួល"
សន្ទុក, ថ្ងៃទី ខែ ឆ្នាំ២០០៧
អភិបាលស្រុកសន្ទុក

លេខ
បានឃើញ និង បញ្ជូនមក
លោកប្រធានមន្ទីរកសិកម្ម
"ដើម្បីពិនិត្យ និង សំរួល"
កំពង់ធំ, ថ្ងៃទី ខែ ឆ្នាំ២០០៧
ប្រធានការិយាល័យជលផល

លេខ
បានឃើញ និង បញ្ជូនមក
ឯកឧត្ដមអភិបាលខេត្ត
"ដើម្បីពិនិត្យ និង សំរួល"
កំពង់ធំ, ថ្ងៃទី ខែ ឆ្នាំ២០០៧
ប្រធានមន្ទីរកសិកម្ម

លេខ
បានឃើញ និង ឯកភាព
កំពង់ធំ, ថ្ងៃទី ខែ ឆ្នាំ២០០៧
អភិបាលខេត្ត

**កំណត់សំគាល់:**

- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ឃុំ
- ផ្លូវ
- ព្រំប្រទល់កន្លែងនេសាទសហគមន៍
- ព្រំប្រទល់ឡូត៍នេសាទ
- កន្លែងនេសាទសំរាប់រាស្ត្រ

**ប្រភពទិន្នន័យ:**

ព្រំប្រទល់រដ្ឋបាល: នាយកដ្ឋានភូមិសាស្ត្រ ២០០៣
ព្រំប្រទល់ឡូត៍នេសាទ: រដ្ឋបាលជលផល
ព្រំប្រទល់កន្លែងនេសាទសហគមន៍: ប្រមូលព័ត៌មានដោយឧបករណ៍ ជីភីអេស
ផ្លូវ - បឹង - ស្ទឹង - ព្រែក: រដ្ឋបាលជលផល ២០០៦

**ប្រព័ន្ធកូអរដោនេ:**

បញ្ចុះបែងភាគប្រើពី: អ៊ុយតេអឹម
ប្រើពីរាងពងក្រពើ: អេវើរែស ១៨៣០
កំណត់បណ្ដាញនៃប្រើពីវិភាគ: យកតាមបណ្ដាញប្រើពីវិភាគឥណ្ឌា ១៩៦០
ផ្នែកផ្ទៃវណ្ណមណ្ឌល លេខ: ៤៨ ខាងជើង

ជ ល ក ត

មាត្រដ្ឋាន ១:៥០.០០០
០ ១ ២គីឡូម៉ែត្រ

**រៀបចំដោយ:**

ក្រុមផែនទី - គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប
ផ្នែកទី ២ (ខេត្តកំពង់ធំ)
ខែ មករា ឆ្នាំ ២០០៧

# បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និង
# គណៈកម្មការសហគមន៍នេសាទ ព្លៅរអភិវឌ្ឍន៍បឹងកណ្តាល

## បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទព្លៅអភិវឌ្ឍន៍បឹងកណ្ដោល
## ឃុំ ព្លៅ ស្រុក សន្ទុក ខេត្តកំពង់ធំ

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | តួនាទីក្នុងគណៈកម្មការ | ហត្ថលេខា |
|---|---|---|---|---|---|---|
| ១ | ស អៀន | ប្រុស | ៣៩ | ព្លៅ | ប្រធាន.សហគ. | |
| ២ | ឃឹម កុសល | ប្រុស | ៤៦ | ព្លៅ | អនុប្រធាន | |
| ៣ | ហែម ឃឹម | ប្រុស | ៣៩ | ព្លៅ | សមាជិក | |
| ៤ | ប៉ាត ស៊ីណែង | ស្រី | ២៥ | ព្លៅ | សមាជិក | |
| ៥ | ស៊ុំ ស៊ន | ប្រុស | ៤៥ | ព្លៅ | សមាជិក | |
| ៦ | មឿង ឃី | ប្រុស | ៤៣ | ព្លៅ | សមាជិក | |
| ៧ | សេង ម៉ៅ | ប្រុស | ៣៨ | ព្លៅ | សមាជិក | |
| ៨ | គុជ ប៉េងងួន | ប្រុស | ៤៥ | ព្លៅ | សមាជិក | |
| ៩ | អាក់ តាំងឃី | ស្រី | ៤៨ | ព្លៅ | សមាជិក | |

ធ្វើនៅព្លៅ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦

ប្រធានគណៈកម្មការសហគមន៍នេសាទ

ព្លៅអភិវឌ្ឍន៍បឹងកណ្ដោល

ស អៀន

បានឃើញ និង បញ្ជាក់ថា

ឈ្មោះនៅក្នុងបញ្ជីខាងលើនេះ គឺជាសមាជិកគណៈកម្មការ

សហគមន៍នេសាទព្លៅអភិវឌ្ឍន៍បឹងកណ្ដោលប្រាកដមែន ។

ព្លៅ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦

មេឃុំព្លៅ

## បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ

### សហគមន៍នេសាទខ្ពោរអភិវឌ្ឍន៍បឹងកណ្ដោល

### ស្រុក សន្ទុក ខេត្តកំពង់ធំ

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | ឃុំ | ថ្ងៃ ខែ ឆ្នាំ ចូលសមាជិក ( ចុះហត្ថលេខាដំបូង) |
|---|---|---|---|---|---|---|
| ១ | ង៉ិន ស៊ើ | ប្រុស | ៤១ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ២ | អេង ខា | ប្រុស | ៤៥ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ៣ | សេក យិន | ស្រី | ៦៥ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ៤ | ទូច រឿន | ស្រី | ៥៤ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ៥ | ជី ប៉ាត់ | ស្រី | ៦៨ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ៦ | ជុំ ថា | ស្រី | ៤២ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ៧ | ប៊ូ រី | ស្រី | ៤៨ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ៨ | អ៊ួង គន | ប្រុស | ៥០ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ៩ | ប៉ែន ស៊ុម | ស្រី | ៥០ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ១០ | ហែម វេត | ស្រី | ៦២ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ១១ | យុន រ៉ុម | ស្រី | ២៥ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ១២ | អ៊ុក ឡៃ | ស្រី | ៤៦ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ១៣ | អ៊ុក ផៃ | ស្រី | ៦៥ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ១៤ | ទ្រៀ ផុន | ស្រី | ៧០ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ១៥ | គុជ សៀ | ស្រី | ៦៥ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |
| ១៦ | ហ៊ុត គ្រាប | ស្រី | ៨០ | ខ្ពោរ | ខ្ពោរ | ១៩-តុលា-២០០៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៧ | ភេម រ៉ន | ស្រី | ៥៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៨ | ម៉ុក ភាព | ស្រី | ៤៥ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៩ | ឃឹម កុសល | ស្រី | ៤០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២០ | ជា ញ៉ូ | ស្រី | ៥១ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២១ | ឈឹម សុកល | ស្រី | ២៩ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២២ | ទ្រី គឹមស៊ីន | ស្រី | ២៧ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២៣ | ជឹម ចាន់នី | ប្រុស | ២០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២៤ | សុំ សិន | ប្រុស | ៤៨ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២៥ | ហែម យាង | ប្រុស | ២១ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២៦ | កែ គឹមឈឹម | ប្រុស | ៣៥ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២៧ | មឿង ឃី | ប្រុស | ៤០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២៨ | ឃឹម សាយ | ប្រុស | ៤២ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ២៩ | យាង រតនា | ស្រី | ២៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៣០ | អ៊ុយ ឃៀង | ស្រី | ៧០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៣១ | នួន ហួរ | ប្រុស | ៣៦ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៣២ | សុំ សេង | ប្រុស | ៤០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៣៣ | ពុធ វ៉ុន | ស្រី | ១៧ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៣៤ | សាំង ខន | ស្រី | ៣៦ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៣៥ | ឃី ខេង | ស្រី | ៣៨ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៣៦ | ស អៀន | ប្រុស | ៣០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៣៧ | ភោគ ខុន | ស្រី | ៤៥ | [illegible] | ខ្មៅ | ១៩-តុលា-២០០៦ |
| ៣៨ | ស៊ុំ រ៉ន | ស្រី | ៤៧ | [illegible] | ខ្មៅ | ១៩-តុលា-២០០៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣៩ | ជុំ ធី | ស្រី | ៣៩ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤០ | ឌឿ ដា | ប្រុស | ៦៤ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤១ | ភោគ រុំ | ស្រី | ៥៦ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤២ | ញ៉ឹក មន | ប្រុស | ៧០ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤៣ | រ៉ង យឹម | ប្រុស | ២៩ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤៤ | គុជ ប៉េងងួន | ប្រុស | ៤០ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤៥ | កង ឈឹម | ប្រុស | ៤៦ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤៦ | អ៊ុំ ផៃ | ប្រុស | ៥០ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤៧ | យឹម សុខែម | ស្រី | ២៧ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤៨ | មុត ឆាយ | ស្រី | ៦១ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៤៩ | សេង មៅ | ស្រី | ៣៨ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥០ | ច័ន្ទ ម៉ន | ស្រី | ៥០ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥១ | ស្រី គេង | ស្រី | ៤០ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥២ | ហួត នាង | ស្រី | ៣០ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥៣ | ហេង តុលា | ស្រី | ២៨ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥៤ | យី យ៉េត | ស្រី | ៤០ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥៥ | ង៉ាន គីមស្រោន់ | ស្រី | ៣០ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥៦ | ប៉ាត់ វ៉ាន់នី | ស្រី | ៣១ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥៧ | ឈើវ គឹមជី | ស្រី | ៣៨ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥៨ | សេង ហ៊ន | ប្រុស | ៣២ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៥៩ | ភឿក លឹម | ប្រុស | [illegible] | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |
| ៦០ | មៅ វ៉ាន់ណា | ប្រុស | ៥៧ | ត្នោ | ត្នោ | ១៩-តុលា-២០០៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ៦១ | ហេង ស៊ីនួន | ស្រី | ៤៧ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៦២ | បាត ណេង | ស្រី | ២៩ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៦៣ | យាង | ស្រី | ៣៧ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៦៤ | ស្រេង គីមឈុង | ស្រី | ៣៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៦៥ | ជ្រុន ស៊ីគ្រាន់ | ស្រី | ២៩ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៦៦ | យឹម សម្បត្តិ | ស្រី | ៣០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៦៧ | យី យឿន | ស្រី | ៣១ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៦៨ | ចាយ គីមសាន់ | ប្រុស | ៣០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៦៩ | ស្រេង តុង | ស្រី | ៤១ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧០ | នៅ វត្ថា | ប្រុស | ២៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧១ | អ៊ុំ សុធា | ប្រុស | ៣៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧២ | ឈួន ថា | ប្រុស | ៤៩ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧៣ | សេក ម៉ុន | ប្រុស | ៥៩ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧៤ | អ៊ិត សែម | ប្រុស | ៥២ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧៥ | ញ៉ាក់ ណាំគា | ប្រុស | ២៨ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧៦ | ជុំ ធីម | ប្រុស | ៤១ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧៧ | ជុំ ខន | ប្រុស | ៥២ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧៨ | កួយ ញាណ | ប្រុស | ៥៣ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៧៩ | ឆេង ខេង | ស្រី | ៤០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៨០ | ឡឿ ប៉ុង | ស្រី | ៦៧ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៨១ | ជី ពៅ | ប្រុស | ២៨ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ៨២ | អួង ឡៅ | ប្រុស | ៧០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ៨៣ | មោញ មិន | ប្រុស | ៦៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៨៤ | គង់ ផុន | ប្រុស | ៧៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៨៥ | ម៉ែន ម៉ិក | ប្រុស | ៦២ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៨៦ | ម៉ែន ពៅ | ស្រី | ៣៨ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៨៧ | ចាន់ រ៉ុម | ស្រី | ៣៨ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៨៨ | ឆែង ណួន | ស្រី | ៥៥ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៨៩ | ស ហៀង | ស្រី | ៤៨ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩០ | កែ វ៉ាត | ប្រុស | ៦៤ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩១ | តាន់ សីហា | ប្រុស | ២៦ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩២ | ជុំ សារុំ | ប្រុស | ៣៦ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩៣ | ឈួន សំណាង | ប្រុស | ២៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩៤ | សូ គាន | ប្រុស | ៤៥ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩៥ | សុខ សេង | ប្រុស | ៦៥ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩៦ | ធូង តាំងសៀ | ប្រុស | ៤០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩៧ | ធូង កែត | ប្រុស | ៣០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩៨ | អ៊ុត ភឿន | ប្រុស | ៣៥ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ៩៩ | ជឹម ហួយ | ស្រី | ៣៤ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១០០ | នៃ សុខាន់ | ស្រី | ៤២ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១០១ | ផន ភាព | ប្រុស | ២៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១០២ | យុន មករា | ប្រុស | ២៥ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១០៣ | ជុំ ខេង | ស្រី | ៤៨ | | ខ្មៅ | ១៩-តុលា-២០០៦ |
| ១០៤ | កែវ ទៃឡម | ស្រី | ៥៥ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ១០៥ | ឈួន គីមយីន | ស្រី | ៣៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១០៦ | ទៀវ នីម | ប្រុស | ២៤ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១០៧ | ជៀម ពុធ | ប្រុស | ៣៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១០៨ | ជួន ជឿន | ស្រី | ៣៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១០៩ | សុង សុខនឿន | ស្រី | ២៣ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១០ | ហាក់ សេង | ប្រុស | ៥៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១១ | ឃឹម សុខឃីម | ស្រី | ២២ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១២ | សូ រើង | ស្រី | ៥៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១៣ | គុយ ខេង | ស្រី | ៧៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១៤ | ស្រេង លៀង | ស្រី | ៤៧ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១៥ | អាក់ តាំងឃី | ស្រី | ៤៨ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១៦ | ជៀម ច្រិប | ស្រី | ២៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១៧ | ភេម រឿន | ស្រី | ៣៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១៨ | ពុធ វត | ស្រី | ៤៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១១៩ | ឡាច មន | ប្រុស | ៥២ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១២០ | យី យន | ស្រី | ៦៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១២១ | ហែម យឹម | ប្រុស | ៣៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១២២ | ហែម នឿន | ស្រី | ៤៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១២៣ | ហ៊ុន លី | ប្រុស | ៧២ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១២៤ | សូ វ៉ង | ស្រី | ៦០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១២៥ | ហ៊ាន ខន | ប្រុស | [illegible] | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១២៦ | វ៉ាន់ វ៉ន | ប្រុស | ៧០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ១២៧ | ស៊ាន់ សុខឃាន់ | ស្រី | ២៧ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១២៨ | ឈីវ អាត | ប្រុស | ៤១ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១២៩ | ឡាយ វុធី | ប្រុស | ២៩ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣០ | ខៀវ ស៊ុំ | ស្រី | ៥២ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣១ | មុំ ឈេន | ប្រុស | ៤៩ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣២ | ប៉ូ ផល្លា | ស្រី | ២៧ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣៣ | ម៉ែន មិត | ប្រុស | ២៦ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣៤ | ចាន់ គៀន | ស្រី | ៦០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣៥ | ទឹម ម៉ាប់ | ស្រី | ៦៦ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣៦ | ឃឹម ហាន | ប្រុស | ២២ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣៧ | ឈឹម អួន | ស្រី | ៣៧ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣៨ | ង៉ោ គីមហ៊ី | ប្រុស | ២៤ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៣៩ | អ៊ឹង គីមខៀវ | ស្រី | ៣៩ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៤០ | ហួត សារ៉ុន | ស្រី | ៣៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៤១ | ជុំ រ៉ា | ប្រុស | ៤៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៤២ | ឡាយ ចូយ | ប្រុស | ៧៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៤៣ | ចាន់ នៃ | ប្រុស | ៤៦ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៤៤ | ឈួន តាយ | ប្រុស | ៦៩ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៤៥ | យុង ឆើត | ប្រុស | ៣៤ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៤៦ | ឡាច ព្រែក | ស្រី | ៣៣ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៤៧ | ជួប សារូ | ស្រី | ៤០ | ខ្មៅ | ខ្មៅ | ១៩-តុលា-២០០៦ |
| ១៤៨ | ចេង ស៊ីថាត | ស្រី | ៤២ | [illegible] | ខ្មៅ | ១៩-តុលា-២០០៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៤៩ | គួន សៀងហៃ | ស្រី | ២៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥០ | ហែម យ៉ុន | ស្រី | ៣២ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥១ | ឆាយ សាន | ប្រុស | ៣០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥២ | ប៉ាត់ វណ្ណា | ប្រុស | ៣១ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥៣ | ម៉ែន គ្រូច | ប្រុស | ២៨ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥៤ | ជា លីម | ប្រុស | ៤៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥៥ | អុច ជា | ស្រី | ៤៣ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥៦ | សុខ សុភា | ស្រី | ៤០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥៧ | ម៉ុក ឡូត | ប្រុស | ៥៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥៨ | យួង វ៉ាង | ស្រី | ៤៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៥៩ | ចេង សឿក | ប្រុស | ៦៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦០ | ស្រេង វេង | ប្រុស | ៧៤ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦១ | គង់ ថា | ប្រុស | ៤៣ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦២ | ឡាយ ស្រិន | ស្រី | ៣៧ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦៣ | ចាន់ គី | ស្រី | ៤៣ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦៤ | ហុង រស់ | ស្រី | ៥៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦៥ | ចាយ សុខូ | ស្រី | ៣៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦៦ | ធូង ខេមរៈ | ប្រុស | ៤១ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦៧ | ឡាយ ស្រៀន | ស្រី | ៤២ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦៨ | ហុង ឈុនអ៊ី | ស្រី | ៥០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៦៩ | តាន់ ឌិន | ប្រុស | [illegible] | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៧០ | ស ឆៃហៀង | ប្រុស | ៥៣ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៧១ | កែវ សុគា | ប្រុស | ២១ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៧២ | ជីប ស្រៀន | ស្រី | ២២ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៧៣ | ហ៊ុន លន់ | ប្រុស | ៦៨ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៧៤ | កែ ហ៊ុន | ប្រុស | ៥៨ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៧៥ | ហិន សូត្រ | ស្រី | ៧៦ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៧៦ | ឌិង មៅ | ស្រី | ៥៤ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៧៧ | ឌិង ចិន្ទា | ស្រី | ៣២ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៧៨ | អៀ ផា | ស្រី | ៣០ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៧៩ | កែ ភី | ស្រី | ៤៥ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |
| ១៨០ | សេក ពក | ប្រុស | ៥៩ | ព្នៅ | ព្នៅ | ១៩-តុលា-២០០៦ |

**សមាជិកសរុប: ១៨០នាក់**

**ស្រី: ៩៨នាក់**

**បានឃើញ និង ចុះក្នុងបញ្ជី**

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ ព្នៅអភិវឌ្ឍន៍បឹងកណ្តាល

ឈ្មោះសហគមន៍នេសាទ : **ព្នៅអភិវឌ្ឍន៍បឹងកណ្តាល**

ភូមិ : *ព្នៅ*

ឃុំ : *ព្នៅ*

ស្រុក : *សន្ទុក*

ខេត្ត : *កំពង់ធំ*

# លក្ខន្តិកៈសហគមន៍នេសាទ

## ជំពូកទី ១
## គោលបំណង និង នាមករណ៍

**ប្រការ ១.-**

លក្ខន្តិកៈនេះមានគោលបំណង ៖

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ ។

**ប្រការ ២.-**

ឈ្មោះសហគមន៍នេសាទព្នៅអភិវឌ្ឍន៍បឹងកណ្ដោល ហៅកាត់ថា ស.ន.ព.អ.ប.ក អាសយដ្ឋាន ផ្ទះលេខ ........... ភូមិព្នៅ ឃុំព្នៅ ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សហគមន៍នេសាទនេះ មានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង ៖

១. ភូមិព្នៅ ឃុំព្នៅ ស្រុកសន្ទុក

មានកម្មវត្ថុ ដើម្បីថែរក្សា ការពារ គ្រប់គ្រង និង អភិវឌ្ឍធនធានជលផលកុងកន្លែងនេសាទសហគមន៍ឱ្យសំបូរឡើងវិញ និងប្រើប្រាស់យូរអង្វែង ព្រមទាំងជួយលើកស្ទួយកម្រិតជីវភាពរស់នៅឱ្យបានប្រសើរឡើងវិញ ។

## ជំពូកទី ២
## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និង សិទ្ធិរបស់សមាជិក

**ប្រការ ៣.-**

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

- មានលំនៅដ្ឋាននៅក្នុងបណ្ដាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង ។

**ប្រការ ៤.-**

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើមានសិទ្ធិ ៖

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍ ។

សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់(១/១០)ឡើងទៅ អាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិកសហគមន៍នេសាទដែលបានស្នើសុំខាងលើនេះ អាចចាត់តំណាងចំនួនបី(៣)នាក់ចូលរួមប្រជុំ ដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ ។

**ប្រការ ៥.-**

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ៖

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និង គណៈកម្មការសហគមន៍នេសាទ បង់ប្រាក់

សមាជិកភាពចំនួន ៥០០ រៀលតាមការសម្រេចរបស់មហាសន្និបាត នៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ

- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន ១.០០០រៀល តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ ។

## ជំពូកទី ៣

## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និង ការបណ្តេញចេញពីសមាជិក

### ប្រការ ៦._

សមាជិកសហគមន៍នេសាទ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ៖

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

### ប្រការ ៧._

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- ការមិនបង់ភាគទានចំនួន ៣ លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ។

## ជំពូកទី ៤

## របៀបរបបកាន់បញ្ជី និង ឯកសារនានា

### ប្រការ ៨._

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ៖

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលស្របច្បាប់ផ្សេងៗទៀត។

## ប្រការ ៩.–

រាល់ការចំណាយថវិកា សហគមន៍ត្រូវអនុវត្តដូចតទៅ ៖

- ការចំណាយពី ១០០រៀល ដល់ ២០.០០០រៀល ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ
- ការចំណាយលើសពី ២០.០០០រៀល ដល់ ១០០.០០០រៀល ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ
- ការចំណាយលើសពី ១០០.០០០ រៀល ឡើងទៅ ត្រូវសម្រេចដោយមហាសន្និបាត។

## ប្រការ ១០.–

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី ៖

- ចំណូល ចំណាយថវិកា
- សារពើភណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

## ប្រការ ១១.–

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ៖

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ
- រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ។

## ជំពូកទី ៥

## គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១២.-**

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និង គ្រប់គ្រងសហគមន៍នេសាទទាំងមូល។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន។

**ប្រការ ១៣.-**

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ(៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណីដែលសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬ អសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី(១/៣)មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី។

**ប្រការ ១៤.-**

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេលប្រាំមួយ(៦)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសំឡេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស។

## ជំពូកទី ៦

## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥.-**

គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល។

**ប្រការ ១៦.-**

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និង ធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យមានរបៀបរៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

**ប្រការ ១៧ .-**

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទដោយមានសំឡេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាល នៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសំលេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព ៖

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាមប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ។

## ជំពូកទី ៧

## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨.-**

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម ៖

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ ។

## ប្រការ ១៩.-

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង១ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំនិងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណី ចាំបាច់សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) យ៉ាងតិច ។

## ប្រការ ២០.-

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ។

## ប្រការ ២១.-

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ៖

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំ និង ទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញ ត្រូវធ្វើឡើងដប់(១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី(៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញ អាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាត ត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ

- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមានវត្តមាន ។

**ប្រការ ២២.-**

មហាសន្និបាតអនុម័ត ៖

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ ។

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣.-**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និង ចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត ។

**ប្រការ ២៤.-**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ គឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី(៣)ទៅប្រាំ(៥)នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិក តាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ ។ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់ ។

**ប្រការ ២៥.-**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ៖

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាត

- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ ។

**ប្រការ ២៦.–**

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ ត្រូវទទួលតួនាទីជាអនុប្រធានជាសមាជិកគណៈកម្មការសហគមន៍នេសាទ តាមលំដាប់លំដោយ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាពដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម ។

## ជំពូកទី ៩
## លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧.–**

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ៖

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សេចក្តីសម្រេចមហាសន្និបាត
- ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៨.–**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច។

**ប្រការ ២៩.–**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ៖

- គណៈកម្មការសហគមន៍នេសាទ ត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន ។

- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់។
- ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និង រដ្ឋបាលជលផល ត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមី ដើម្បីដោះស្រាយតាមផ្លូវច្បាប់។

**ប្រការ ៣០.-**

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន។

## ជំពូកទី ១០
## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១.-**

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវធ្វើឡើងដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣)នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះ ត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបាន លុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្តាលនៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៣២.-**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅព្នៅ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

# ព្លៅរអតិវឌ្ឍន៍បឹងកណ្ដាល

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និង មានរបៀបរៀបរយល្អ សហគមន៍នេសាទព្នៅអភិវឌ្ឍន៍បឹងកណ្ដាល សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ៖

**ប្រការ ១.–**

គណៈកម្មការ និង សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនាព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ។

**ប្រការ ២.–**

គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ៖

- ចំពោះសមាជិកសហគមន៍នេសាទ ឬ បុគ្គលដទៃទៀតត្រូវសង ឬ ទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្ដែងតាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណី មិនព្រមសងត្រូវដាក់ជូនមហាសន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត។ ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបាន គឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន។

**ប្រការ ៣ .–**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទ តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួន៣ ដង ជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ។

ករណីនៅតែមិនរាងចាលគណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

**ប្រការ ៤.–**

សិទ្ធិដាក់ទណ្ឌកម្ម ៖

**ក -គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ និងលើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ

- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និង រាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍ ។

**៩-មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន ។

## ប្រការ ៥.-

សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈឧបករណ៍នេសាទដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ។

## ប្រការ ៦.-

សមាជិកសហគមន៍នេសាទ អាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារនៅក្នុងរដូវបើកនេសាទ ដូចមានចែងខាងក្រោម ៖

- មងប្រវែងមិនលើសពី ១០០ម៉ែត្រ
- អួនប្រវែងមិនលើសពី ៣០ម៉ែត្រ
- អញ្ចងប្រវែងមិនលើសពី ៥ម៉ែត្រ
- សំណាញ់ប្រវែងមិនលើស ៦ម៉ែត្រ
- សន្ទូចរនងមិនលើសពី ២០០ផ្លែ
- លបចំនួនមិនលើសពី ១០គ្រឿង
- លាន់ចំនួនមិនលើសពី ៣០លាន់

**ប្រការ ៧.–**

សមាជិកសហគមន៍នេសាទដែល ៖

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និង កាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈ ត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត

- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផល ត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ និងកាប់ឆ្ការរានព្រៃលិចទឹក ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ស្តីពីជលផល លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវផ្អាកការនេសាទទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីដោះស្រាយតាមច្បាប់ ។

**ប្រការ៨.–**

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការ គ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទមិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ ។

**ប្រការ ៩.–**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ ។

ធ្វើនៅព្រៅ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦

**ប្រធានគណៈកម្មការសហគមន៍នេសាទ**




## តួនាទី និង ភារកិច្ចរបស់គណៈកម្មការសហគមន៍នេសាទព្រៀងអភិវឌ្ឍន៍បឹងកណ្ដាល

១- **លោក *ស អៀន*** ប្រធានគណៈកម្មការសហគមន៍នេសាទ :

- *ដឹកនាំ គ្រប់គ្រងសកម្មភាពការងារសហគមន៍នេសាទទាំងមូល និងស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីគ្រប់អង្គការ ស្ថាប័ននានា*
- *សម្របសម្រួលប្រជុំរបស់សហគមន៍នេសាទ និងដោះស្រាយបញ្ហាផ្សេងៗដែលកើតមានក្នុងសហគមន៍នេសាទ*
- *ទទួលខុសត្រូវគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់សហគមន៍នេសាទ ។*

២- **លោក *យឹម កុសល*** អនុប្រធានគណៈកម្មការសហគមន៍នេសាទ :

- *បំពេញតួនាទីដឹកនាំ និងទទួលខុសត្រូវការងារជំនួសមុខឱ្យប្រធាននៅពេលប្រធានអវត្តមាន*
- *ទទួលបន្ទុកព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទ*
- *កសាងភាពជាដៃគូជាមួយប្រធានភូមិ ក្រុមប្រឹក្សាឃុំ ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា*
- *ទទួលខុសត្រូវគ្រប់គ្រងផ្នែកការងាររដ្ឋបាលរបស់សហគមន៍នេសាទ*
- *ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន ។*

៣- **លោក ហែម យឹម** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុករដ្ឋបាល និងលេខាធិការ :

- *រៀបចំបញ្ជីរាយនាមគណៈកម្មការ និងសមាជិកសហគមន៍នេសាទ*
- *ទទួលពាក្យអ្នកស្ម័គ្រចិត្តសុំចូលជាសមាជិកសហគមន៍នេសាទថ្មី*
- *ធ្វើកំណត់ហេតុ របាយការណ៍ និងបញ្ជីវត្តមានរាល់កិច្ចប្រជុំទាំងអស់*
- *ចងក្រង និងរក្សាទុកឯកសារផ្សេងៗរបស់សហគមន៍នេសាទ ។*

៤- **លោកស្រី ពិត ស៊ីណេង** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកអប់រំ និងផ្សព្វផ្សាយ :

- *រៀបចំចាត់ចែងឯកសារ សេចក្តីជូនដំណឹង ស្លាកសញ្ញា និងផ្ទាំងរូបភាពផ្សេងៗសម្រាប់ផ្សព្វផ្សាយ*
- *អប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ សេចក្តីសម្រេចនានារបស់គណៈកម្មការសហគមន៍នេសាទ មហាសន្និបាត និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យជលផល*
- *ធ្វើរបាយការណ៍អំពីការងារអប់រំ និងផ្សព្វផ្សាយជូនសហគមន៍នេសាទ ។*

៥- **លោក ស៊ុំ ស៊ន** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកផែនការគ្រប់គ្រង ស្ថិតិ និងអភិវឌ្ឍន៍សហគមន៍នេសាទ :

- *ស្រង់ និងធ្វើស្ថិតិអំពីប្រភេទធនធានជលផល ដែននេសាទ ឧបករណ៍នេសាទដែលមាននៅក្នុងសហគមន៍នេសាទ*
- *រៀបចំបញ្ជីសារពើភណ្ឌរបស់សហគមន៍នេសាទ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍*
- *រៀបចំកម្មវិធី និងគម្រោងផែនការអភិវឌ្ឍន៍សហគមន៍នេសាទ*
- *តាមដាន និងវាយតម្លៃការអនុវត្តផែនការរបស់សហគមន៍នេសាទ ។*

៦- **លោក មឿង យី** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកការពារនិងអភិរក្សធនធានជលផល :

- *ល្បាត ថែរក្សា ការពារធនធានជលផល និងទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍*
- *កសាងផែនការយុទ្ធសាស្ត្រ និងវិធានការការពារធនធានជលផលក្នុងកន្លែងនេសាទសហគមន៍*
- *រាយការណ៍ ចូលរួមសហការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍*
- *ធ្វើរបាយការណ៍អំពីការងារអភិរក្ស និងបង្ក្រាបរាល់បទល្មើសជលផលជូនសហគមន៍នេសាទ ។*

៧- **លោកស្រី សេង ម៉ៅ** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកទំនាក់ទំនងនិងសហប្រតិបត្តិការ :

- *ធ្វើទំនាក់ទំនងកសាងភាពជាដៃគូជាមួយប្រធានភូមិ ក្រុមប្រឹក្សាឃុំ ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា*
- *ជួយស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីរដ្ឋបាលជលផល ស្ថាប័នជំនាញ និងអង្គការជាតិ អន្តរជាតិនានាសម្រាប់អនុវត្តន៍ដំណើរការសហគមន៍នេសាទ ។*

៨- **លោក គុជ ម៉េងងួន** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកគណនេយ្យ :

- *គ្រប់គ្រងគណនី កត់ត្រា និងចុះបញ្ជីថវិកាចំណូល ចំណាយរបស់សហគមន៍នេសាទឱ្យបានត្រឹមត្រូវ*
- *ចាត់ចែងថវិកាសម្រាប់ធ្វើការចំណាយដោយមានវិក័យបត្រ និងបញ្ជីកត់ត្រាត្រឹមត្រូវ*

- *រៀបចំគម្រោងផែនការចំណូល ចំណាយរបស់សហគមន៍នេសាទ*
- *ធ្វើរបាយការណ៍បូកសរុប របាយការណ៍អំពីស្ថានភាពចំណូល ចំណាយរបស់សហគមន៍នេសាទប្រចាំខែ ត្រីមាស និងឆ្នាំ*
- *រក្សាទុករាល់ឯកសារចំណូល ចំណាយរបស់សហគមន៍នេសាទ ។*

៩- **លោកស្រី *អាក់ តាំងយី*** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកបេឡា :

- *គ្រប់គ្រង ថែរក្សាសាច់ប្រាក់របស់សហគមន៍នេសាទ និងបើកប្រាក់*
- *ធ្វើរបាយការណ៍ផ្ទៀងផ្ទាត់ របាយការណ៍អំពីការចំណូល ចំណាយរបស់សហគមន៍នេសាទប្រចាំខែ ត្រីមាស និងឆ្នាំ*
- *រក្សាទុករាល់ឯកសារចំណូល ចំណាយសាច់ប្រាក់របស់សហគមន៍នេសាទ ។*

បានឯកភាពបែងចែកតួនាទី និងភារកិច្ចដោយការស្ម័គ្រចិត្ត

នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦

**គណៈកម្មការសហគមន៍នេសាទ**

១- **លោក *ស អៀន*** ............

២- **លោក *យឹម កុសល*** ............

៣- **លោក *ហែម យឹម*** ............

៤- **លោកស្រី *ប៉ាន ស៊ីណាង*** ............

៥- **លោក *ស៊ុំ ស៊ីន*** ............

៦- **លោក *មៀង យី*** ............

៧- **លោកស្រី *សេង ម៉ៅ*** ............

៨- **លោក *គុជ ប៉េងងួន*** ............

៩- **លោកស្រី *អាក់ តាំងយី*** ............

# សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ
# ព្លោរអតិវឌ្ឍន៍បឹងកណ្តាល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីថ្លែងការណ៍
# នៃការបង្កើតសហគមន៍នេសាទព្នៅអភិវឌ្ឍន៍បឹងកណ្តោល

យោងតាមគំនិតផ្តួចផ្តើមដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានៅក្នុងក្រប ខ័ណ្ឌនៃកំណែទម្រង់វិស័យជលផលទូទាំងប្រទេសចាប់ពីចុងឆ្នាំ ២០០០មក និង យោងតាមព្រះ រាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ ច្បាប់ស្តីពីជលផល និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភូមិព្នៅ ឃុំព្នៅបានស្ម័គ្រចិត្តរួមគ្នាបង្កើតជាសហគមន៍នេសាទ ដើម្បីចូលរួមសហការជាមួយអាជ្ញាធរភូមិ ឃុំ និងរដ្ឋបាលជលផលក្នុងការថែរក្សា ការពារ គ្រប់គ្រងធនធានធម្មជាតិ និងទប់ស្កាត់រាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍ ព្រមទាំងធានាឱ្យសមាជិកសហគមន៍នេសាទទាំងអស់មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព និងមានបំណងលើកស្ទួយកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ដូចចែងក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ដោយសារមានការជួយសម្របសម្រួលពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ផ្នែកទី២ (TSEMP C2) របស់ខណ្ឌរដ្ឋបាលជលផលកំពង់ធំ អាជ្ញាធរភូមិ និងក្រុមប្រឹក្សាឃុំព្នៅ បានរៀបចំបើកមហាសន្និបាតបង្កើតសហគមន៍នេសាទកំណើតដំបូងនៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦ ដែលមានអ្នកចូលរួមចំនួន **១៨០**នាក់ ក្នុងនោះមានស្រី **៩៨**នាក់ ដើម្បីអនុម័តសមាជិកសហគមន៍នេសាទពេញសិទ្ធិ អនុម័តឈ្មោះសហគមន៍នេសាទ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងសហគមន៍នេសាទ និងបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទចំនួន**៩**រូប ក្នុងនោះមានស្ត្រី**៣**រូប សម្រាប់ដឹកនាំសហគមន៍នេសាទដែលមានកន្លែងនេសាទសហគមន៍មានទំហំផ្ទៃក្រឡាចំនួន **៩៧៥** ហិកតា។

បន្ទាប់ពីបានទទួលស្គាល់សហគមន៍នេសាទយើងខ្ញុំ តាមរយៈមហាសន្និបាតកំណើតដំបូងមក ខ្ញុំបាទជាប្រធានគណៈកម្មការសហគមន៍នេសាទដែលជាតំណាងឱ្យសមាជិកសមាជិកាសហគមន៍នេសាទទាំងអស់ សូមសន្យាថានឹងខិតខំដឹកនាំ គ្រប់គ្រងសហគមន៍នេសាទឱ្យបានល្អដោយប្រកាន់ភ្ជាប់នូវភាពស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្តាបនា និងចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ព្រមទាំងខិតខំរៀនសូត្រ កសាងទំនាក់ទំនងជាមួយគ្រប់អង្គភាពស្ថាប័នរដ្ឋ អង្គការនានាដើម្បីស្វែងរកអ្នកជួយឧបត្ថម្ភគាំទ្រ បច្ចេកទេស និងថវិកាសម្រាប់ដំណើរការរីកចំរើនរបស់សហគមន៍នេសាទ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំមេត្តាពិនិត្យ និងសម្រេចដើម្បីសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ព្នៅអភិវឌ្ឍន៍បឹងកណ្តោល ដោយអនុគ្រោះ។

ធ្វើនៅភូមិព្នៅ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

# លិខិតស្នើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
# ព្នៅអភិវឌ្ឍន៍បឹងកណ្តាល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រធានគណៈកម្មការសហគមន៍នេសាទព្នៅអភិវឌ្ឍន៍បឹងកណ្តោល**

**សូមគោរពជូន**

**លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**កម្មវត្ថុ** : សំណើចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ព្នៅអភិវឌ្ឍន៍បឹងកណ្តោល ។

**យោង** : - អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ។

- សេចក្តីសម្រេចរបស់មហាសន្និបាតសហគមន៍នេសាទកំណើតដំបូង ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៦ ។

**លិខិតភ្ជាប់** : កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ព្នៅអភិវឌ្ឍន៍បឹងកណ្តោល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកនាយមេត្តាជ្រាបថា សហគមន៍នេសាទព្នៅអភិវឌ្ឍន៍បឹងកណ្តោលបានបង្កើតឡើង ដោយការស្ម័គ្រចិត្ត និង មានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងភូមិព្នៅ ឃុំព្នៅ និងមានការជួយសម្របសម្រួលពីគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ផ្នែកទី២ (TSEMP C2) របស់ខណ្ឌរដ្ឋបាលជលផលកំពង់ធំ អាជ្ញាធរភូមិ និងក្រុមប្រឹក្សាឃុំព្នៅ។ សហគមន៍នេសាទមានគណៈកម្មការសហគមន៍នេសាទចំនួន **៩**រូប ក្នុងនោះមានស្ត្រី **៣**រូប និងមានសមាជិកសហគមន៍សរុបចំនួន **១៨០**នាក់ ស្រីចំនួន **៩៨**នាក់។ បន្ទាប់ពីបានបង្កើតរួចមក សហគមន៍នេសាទព្នៅអភិវឌ្ឍន៍បឹងកណ្តោលបានដឹកនាំ និងចូលរួមអនុវត្តដំណើរការសហគមន៍នេសាទយ៉ាងសកម្មជាមួយនិងការចូលរួមឧបត្ថម្ភគាំទ្រពីសមត្ថកិច្ចរដ្ឋបាលជលផល និងអាជ្ញាធរភូមិ ឃុំ។ ម្យ៉ាងទៀត គណៈកម្មការសហគមន៍នេសាទបានរៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ផែនទី និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រួចជាស្រេច ហើយនឹងគ្រោងរៀបចំកម្មវិធីចុះកិច្ចព្រមព្រៀងសហគមន៍នេសាទជាមួយលោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ ដែលនឹងប្រព្រឹត្តធ្វើឡើង នាថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៧ នៅការិយាល័យផ្នែកអនុវត្តន៍គម្រោង (PIU) ខេត្តកំពង់ធំ ។

<u>សូមជូនភ្ជាប់មកជាមួយនូវ</u> :

១- កិច្ចព្រមព្រៀងសហគមន៍នេសាទកន្លែងនេសាទសហគមន៍ ។

២- ផែនទីកន្លែងនេសាទសហគមន៍មាត្រដ្ឋាន ១/៥០.០០០ ។

៣- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ ។

៤- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ។

៥- សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ ។

អាស្រ័យហេតុនេះ សូមលោកនាយមេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។

ធ្វើនៅភូមិព្នៅ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

# ឯកសារផ្សេង ៗ